# សេចក្តីប្រកាសព័ត៌មាន

ឯកឧត្តម អាឡិកសានឌ័រ ខ្មេនត៍ (H.E. Alexander KMENTT)
នាយកសម្រាប់ការរំសាយសព្វាវុធ
រដ្ឋមន្ត្រីការបរទេសអូទ្រីស

អ្នកយកព័ត៌មានកម្ពុជាៈ

តាងនាមឲ្យរដ្ឋាភិបាលអូទ្រីស ខ្ញុំមានបីតិសោមនស្សដែល ក្នុងពេលពីរបីនាទីខាងមុខនេះ តាងនាមឲ្យប្រទេសអូទ្រីស ខ្ញុំនឹងចុះហត្ថលេខាលើគោលការណ៍ភាពជាដៃគូសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិសកម្មភាពមីន ជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្របគ្នាជាមួយនឹងការសន្យាផ្តល់ជំនួយជាទឹកប្រាក់ ៤០០.០០០ អឺរ៉ូ (ឬ ជាង ២ ពាន់លានរៀល) នៅក្នុងរយៈពេល ២ ឆ្នាំខាងមុខ។

ប្រាក់ចំនួន ៣០០.០០០ អឺរ៉ូនៃជំនួយនេះ នឹងត្រូវបានប្រើដើម្បីជួយគាំទ្រសកម្មភាពបោសសម្អាតមីន និង ប្រាក់ចំនួន ១០០.០០០ អឺរ៉ូ សម្រាប់គម្រោងជួយជនរងគ្រោះ។

នេះគឺជាលើកទីមួយដែលប្រទេសអូទ្រីសរួមវិភាគទានក្នុងលក្ខណៈទ្វេភាគីជាមួយប្រទេសកម្ពុជា ដល់ដំណោះស្រាយអំពីគ្រាប់មីននិងកាកសំណល់សង្គ្រាមដ៏ឃោឃៅដែលប្រទេសម្ចាស់ផ្ទះដ៏រាក់ទាក់នេះត្រូវដោះស្រាយ។

សូមអរគុណ